friends international

Together, building futures.



#everydayheroes #ThinkFamilies #weareChildSafe #ngo #recruitment #job #opportunity #SiemReap #education #teaching #peopledevelopment #khmerspeaker #socialwork #childprotection

# អ្នកជួសជុលម៉ូតូ

## សួស្តីអ្នកទាំងអស់គ្នា ពីកម្មវិធីកល្យាណមិត្ត ខេត្តសៀមរាប!

តើអ្នកមានជំនាញ និងបទពិសោធន៍បើកហាងជួសជុល ឬធ្វើការក្នុងហាងជួសជុលម៉ូតូដែរឬទេ? តើអ្នករីករាយក្នុងការបង្ហាត់បង្រៀនយុវវ័យនូវជំនាញនេះទេ?

ប្រសិនបើអ្នកឆ្លើយថា *"បាទ ឬ ចាស"* នោះអ្នកប្រហែលជាបេក្ខជន ឬបេក្ខនារីដែលយើងត្រូវការហើយ!

អង្គការ ហ្វ្រេនស្ស អ៊ិនធើណាសិនណល (កម្មវិធីកល្យាណមិត្ត ខេត្តសៀមរាប) កំពុងបើកសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជួសជុលម៉ូតូ ដែលមានទីតាំងស្ថិតនៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប ។ យើងផ្តល់ការងារដល់អ្នក និងផ្តល់ឱកាសឱ្យអ្នកបានរៀនសូត្រពីមនុស្សផ្សេងទៀតនៅជុំវិញពិភពលោក ។ មិនត្រឹមតែប៉ុណ្ណោះ កន្លែងរបស់យើងបានផ្តល់ឱ្យយុវវ័យបានរៀនសូត្រអំពីការជួសជុលម៉ូតូ ការផ្តល់សេវាកម្មឱ្យអតិថិជន និងរៀនពីការរៀបចំអាកប្បកិរិយាឱ្យបានសមរម្យនៅកន្លែងការងារផងដែរ ។ ទាំងអស់នេះគឺជាកត្តាសំខាន់ ព្រោះវាជួយឱ្យពួកគេងាយស្រួលក្នុងការស្វែងរកការងារធ្វើ និងប្រែក្លាយពួកគេទៅជាយុវវ័យប្រកបដោយឯករាជ្យ ទន្ទឹមនឹងនោះដែរ អ្នកក៏ជាបុគ្គលគំរូម្នាក់សម្រាប់យុវវ័យផងដែរ ។

**ខាងក្រោមនេះជាការពណ៌នាអំពីអ្វីដែលអ្នកគួរមាន៖**

- ជាអ្នកស្រលាញ់អាជីពជួសជុលម៉ូតូ និងរីករាយក្នុងការបង្ហាត់បង្ហាញ និងចែករំលែកជំនាញរបស់ខ្លួនទៅដល់យុវវ័យ ឬអាណាព្យាបាលដែលស្រលាញ់ជំនាញនេះ
- មានជំនាញវិជ្ជាជីវៈច្បាស់លាស់ (បើមានជំនាញកែច្នៃម៉ូតូកាន់តែល្អ) មានបទពិសោធន៍ល្អៗកន្លងមកក្នុងការបង្រៀនសិស្ស និងការគ្រប់គ្រងថ្នាក់រៀន
- ជាអ្នកចូលចិត្តធ្វើការជាក្រុម ជាពិសេសការងារដ៏មមាញឹកនៅក្នុងថ្នាក់រៀនដែលមានសិស្សច្រើន
- ការងារមានការបត់បែន រួមទាំងពេលវេលា ។

**ទំនួលខុសត្រូវសំខាន់ៗរួមមាន៖**

- ធ្វើការជាមួយក្រុមការងារ ដើម្បីរក្សាហាងឱ្យមានភាពទាក់ទាញ និងឧបករណ៍ប្រើប្រាស់ស្អាតមានអនាម័យ និងសុវត្ថិភាព
- បង្ហាត់បង្ហាញសិស្ស និងអ្នកហាត់ការ ពីរបៀប និងការផ្តល់សេវាកម្មដែលមានគុណភាពជូនអតិថិជន
- ពិភាក្សាជាមួយក្រុមការងារជាប្រចាំ ដើម្បីពង្រឹងលើគុណភាពនៃការបណ្តុះបណ្តាល
- ត្រួតពិនិត្យគ្រឿងបន្លាស់ក្នុងស្តុក និងធ្វើការបញ្ជាទិញចូលថែមតាមម្រូវការជាក់ស្តែង
- រៀបចំកាលវិភាគនៃការបណ្តុះបណ្តាល គ្រប់គ្រងវត្តមានសិស្ស និងធ្វើរបាយការណ៍ ។

**ព័ត៌មានបន្ថែមអំពីការដាក់ពាក្យ**

បើមានចំណាប់អារម្មណ៍ សូមផ្ញើប្រវត្តិរូបសង្ខេបរបស់អ្នកមកកាន់ទីនេះតាមរយៈអ៊ីមែល៖

✉ *hr.kaliyanmith@friends-international.org*

*+855 12 574 635*

*Link Telegram: https://t.me/Savong1982*

បេក្ខជន ឬបេក្ខនារីទាំងអស់នឹងឆ្លងកាត់ការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើគោលការណ៍ការការពារកុមារ និងកិច្ចការពារប្រឆាំងនឹងការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ *(Beneficiary Protection Policy and PSEA Policy)* ។

Friends team